# ក្មេងហើយនិងការចាប់ចិត្តជាខ្លាំងនឹងភ្លើង

Fact Sheet 15 – Community Risk Management. Revised 28/09/2004 - Khmer

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## តើកូនលោកអ្នកមាន *ការចាប់ចិត្តជាខ្លាំង* នឹងភ្លើងឬទេ?

កូនក្មេងជាច្រើន, ហើយជាពិសេសក្មេងប្រុស, ប្រហែលជាមានការចាប់អារម្មណ៍នឹងភ្លើង ឬលេងដែកកេះ ឬឈើគូសនៅក្នុងជំណាក់កាលខ្លះ ។ អ្នកដែលមានជំនាញខាងសុខភាពបានទទួលស្គាល់ថាការចាប់អារម្មណ៍នឹងភ្លើងរបស់កូនក្មេងគឺពិតជាធម្មតា ក៏ប៉ុន្តែការប្រយ័ត្នប្រយែងគឺចាំបាច់ណាស់ដើម្បីធ្វើឲ្យប្រាកដថាកូនរបស់លោកអ្នកមិនលោកភ្លើង ឬធ្វើឲ្យមានការខូចខាតអ្វីមួយដោយហេតុពីការចង់ដឹងចង់ឃើញនេះ ។

## មានមូលហេតុផ្សេងៗដែលកូនក្មេងចាប់ផ្តើមដុតភ្លើង, មូលហេតុខ្លះនៃមូលហេតុទាំងនេះគឺមាន៖

- ☐ ការចង់ដឹងចង់ឃើញហើយនិងការចាប់ចិត្តជាខ្លាំងដែលគេទទួលស្គាល់ថាជាភាគមួយនៃឥរិយាបថក្នុងការរៀនទូទៅ ។
- ☐ កូនក្មេងខ្លះប្រហែលជាចាប់ផ្តើមដុតភ្លើងដែលជាភាគមួយនៃការស្វែងរកឲ្យគេចាប់អារម្មណ៍មកលើខ្លួន ។
- ☐ ការកៀបសង្កត់ពីក្មេងឯទៀតដែលមានអាយុស្របាលគ្នា អាចជាឥទ្ធិពលមួយដែលបណ្តាលឲ្យមានការដុតភ្លើង ។
- ☐ គួរឲ្យស្តាយណាស់, ក្មេងខ្លះដែលមានការឈឺចាប់ក្នុងចិត្តដោយសារកំហឹង ឬការសងសឹកនោះ, ប្រហែលជាដុតភ្លើងហើយ ។
- ☐ ចំពោះក្មេងខ្លះ, វាមានកត្តានៃអំពើរបិុលរប៉ូចព្យាបាទមួយដែលរាប់បញ្ចូលទៅក្នុងការដុតភ្លើងដែរ ។
- ☐ អ្នកមានជំនាញខាងសុខភាពទូន្មានថា ក្មេងមួយភាគតូចដែលមានអារម្មណ៍មិនល្អចំពោះការចាប់ចិត្តជាខ្លាំងនឹងភ្លើង នឹងត្រូវការការព្យាបាលសុខភាពពីអ្នកមានជំនាញខាងនេះ ។

***ជារឿយៗក្មេងមិនបានដឹងថាអណ្តាតភ្លើងដ៏តូចមួយអាចរីករាលដាលទៅជាភ្លើងដែលប្រកបដោយគ្រោះថ្នាក់មួយនោះទេ ។***

## តើលោកអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយបង្ការកុំឲ្យកូនលោកអ្នកមានការចាប់ចិត្តជាខ្លាំងទៅនឹងភ្លើងនោះ? ។

- ☐ សូមដាក់គ្រឿងឲ្យសញ្ញាពេលមានផ្សែង (smoke alarms) ហើយធ្វើតេស្តជារឿយៗជាមួយគ្រួសារលោកអ្នក ហើយនិងដូរថ្មប្រចាំឆ្នាំផង ។
- ☐ ធ្វើឲ្យកូនលោកអ្នកមានការពាក់ពិននឹងការធ្វើផែនការគេចចេញពីផ្ទះ ហើយនាំគ្នាហាត់តាមជារឿយៗផងដែរ ។
- ☐ សូមទុកដាក់ឈើគូសឬដែកកេះដោយសុវត្ថិភាពជានិច្ច ។ ក្មេងនឹងឡើងទៅយករបស់ទាំងនោះ ។
- ☐ សូមបង្ហាត់កូនលោកអ្នកថាភ្លើងមិនមែនជា *ប្រដាប់ក្មេងលេងទេ* ក៏ប៉ុន្តែភ្លើងជា *ឧបករណ៍* ដែលមានប្រយោជន៍សំរាប់ដាំស្លឬដុតកំដៅពេលណាមនុស្សធំប្រើវាដោយសុវត្ថិភាពនិងដោយមានការទទួលខុសត្រូវផងដែរ ។
- ☐ សូមកុំប្រើកូនលោកអ្នកយកឈើគូស ឬដែកកេះឲ្យលោកអ្នក ។ ក្មេងរៀនតាមគំរូហើយនិងធ្វើត្រាប់តាមឥរិយាបថរបស់មនុស្សធំ ។
- ☐ សូមលើកទឹកចិត្តក្មេងតូចៗឲ្យយកឈើគូស ឬដែកកេះណាមួយដែលគេបានរកឃើញមកឲ្យលោកអ្នក ហើយសរសើរគេដែលបានធ្វើអំពើដោយទទួលការខុសត្រូវ ។
- ☐ សូមកុំព្រងើយកន្តើយនឹងភស្តុតាងនៃការលេងភ្លើង ដូចជាដុតខោអាវ ឬមានឈើគូសឬ ដែកកេះនៅក្នុងហោប៉ៅ ។
- ☐ សូមធ្វើឲ្យប្រាកដថាកូនលោកអ្នកត្រូវបានត្រួតមើលគ្រប់ពេលវេលា ។

**ប្រសិនបើលោកអ្នកមានកង្វល់អំពីការចាប់ចិត្តជាខ្លាំងនឹងភ្លើងរបស់កូនលោកអ្នក, សូមទូរស័ព្ទ**

**នៅ NSW តាមលេខ ១៨០០ ៦០០ ៧០០, ឬ នៅ ACT តាមលេខ ៦២០៧ ៩០៣២**

**ចំពោះពត៍មានថែមទៀត សូមទាក់ទងស្ថានីយ៍រលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

## ចំណុចសំខាន់ៗនៃសុវត្ថិភាពនៃការចាប់ចិត្តជាខ្លាំងនឹងភ្លើង

- បង្ហាត់ក្មេងធំៗនូវរបៀបប្រើឈើគូសនិងដុតភ្លើងដោយសុវត្ថិភាព, ហើយនិងបញ្ជាក់គេពីសារៈសំខាន់នៃការដុតភ្លើងនៅក្នុងវត្តមានមនុស្សធំតែប៉ុណ្ណោះ ។
- សូមដឹងថាក្មេងតូចៗប្រហែលលេងនឹងភ្លើងនៅក្នុងបន្ទប់ដេករបស់គេ ។
- នៅពេលលោកអ្នកទទួលទានដំណេក លោកអ្នកនឹងមិនធុំក្លិនផ្សែងទេ ហើយតាមការពិតវានឹងធ្វើឲ្យលោកអ្នកដេកលក់ស៊ុបថែមទៀតផង ។

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ ០០០**